**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ [illegible]

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោមៈ

១-កញ្ចប់"ក"៖ ការផ្គត់ផ្គង់នាឡិកាទឹកមេកានិច-ខ្នាតតូច
២-កញ្ចប់"ខ"៖ ការផ្គត់ផ្គង់កំបោរ
៣-កញ្ចប់"គ"៖ ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធផលិតកម្ម
៤-កញ្ចប់"ឃ"៖ ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី
៥-កញ្ចប់"ង"៖ ការផ្គត់ផ្គង់សម្ភារតភ្ជាប់សម្រាប់ជួសជុលបំពង់ប៉េអ៊ី
៦-កញ្ចប់"ច"៖ ការផ្គត់ផ្គង់សម្ភារតភ្ជាប់សម្រាប់ជួសជុលបំពង់ដែក

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០នាទី) ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល សម្រាប់កញ្ចប់"ក,ខ,ច", ៣០០,០០០រៀល សម្រាប់កញ្ចប់"គ,ង" និង ៤០០,០០០រៀល សម្រាប់កញ្ចប់"ឃ"។

កាលបរិច្ឆេទបង្ហាញគ្រឿងបន្លាស់ប្រព័ន្ធផលិតកម្ម និងគ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០៩:០០នាទីព្រឹក។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធផលិតកម្ម និងគ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី គឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ កញ្ចប់"ក"វេលាម៉ោង១៤:០០នាទី, កញ្ចប់"ខ"វេលាម៉ោង១៤:១៥នាទី, កញ្ចប់"គ"វេលាម៉ោង១៤:៣០នាទី, កញ្ចប់"ឃ"វេលាម៉ោង១៤:៤៥នាទី, កញ្ចប់"ង"វេលាម៉ោង ១៥:០០នាទី និង កញ្ចប់"ច"វេលាម៉ោង១៥:១៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជូ ផល្លា**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh